ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៤

លេខ: ៥២ សរ.សរ

# សេចក្តីសម្រេច
# ការបង្កើតគណៈកម្មការដើម្បីរៀបចំ
# "មហោស្រពសិល្បៈជនជាតិដើមអាស៊ាន"
# ដែលនឹងប្រព្រឹត្តទៅ ពីថ្ងៃទី១៩-២៣ ខែវិច្ឆិកា ឆ្នាំ២០១៤
# នៅរាជធានីភ្នំពេញ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងការចាំបាច់ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១**: ត្រូវបានបង្កើតគណៈកម្មការកណ្តាល ដើម្បីរៀបចំ "មហោស្រពសិល្បៈជនជាតិដើមអាស៊ាន" ដែលនឹងប្រព្រឹត្ត ទៅចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ ដូចមានសមាសភាពខាងក្រោម៖

| | |
|---|---|
| ១. លោកជំទាវ ភឿង សកុណា | ប្រធាន |
| ២. ឯកឧត្តម សំរ៉ាំង កំសាន្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម អ៊ុន ទឹម | អនុប្រធាន |
| ៤. ឯកឧត្តម មិន ចណ្ឌីណារុធ | អនុប្រធាន |
| ៥. ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវត្ថ | សមាជិក |
| ៦. ឯកឧត្តម ហាប់ ទូច | សមាជិក |
| ៧. ឯកឧត្តមបណ្ឌិត បុង សុវត្ថិ | សមាជិក |

គណៈកម្មការនេះមានតួនាទី និងភារៈកិច្ច ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការរៀបចំ "មហោស្រពសិល្បៈជនជាតិដើមអាស៊ាន" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យខ្ពស់។

- សេនាធិការផ្ទាល់ក្នុងការរៀបចំ "មហោស្រពសិល្បៈជនជាតិដើមអាស៊ាន" ដឹកនាំ ត្រួតពិនិត្យ ដោះស្រាយរាល់បញ្ហារបស់អនុគណៈកម្មការជំនាញ។
- រៀបចំគម្រោងចំណាយ និងផ្គត់ផ្គង់ថវិកា កសាងឯកសាររដ្ឋបាល បោះពុម្ព ចែកចាយ និងផ្សព្វផ្សាយព័ត៌មានតាមគ្រប់រូបភាព។

**ប្រការ២:** ត្រូវបានបង្កើតអនុគណៈកម្មការមួយចំនួន សម្រាប់ជួយការងារដល់គណៈកម្មការកណ្តាល ដែលមានសមាសភាព និងភារៈកិច្ច ដូចខាងក្រោម៖

**១. អនុគណៈកម្មការលេខាធិការដ្ឋាន**

| | |
|---|---|
| ១. ឯកឧត្តម អ៊ុន ទឹម | ប្រធាន |
| ២. ឯកឧត្តម មិន ចណ្ឌីណារុធ | អនុប្រធាន |
| ៣. ឯកឧត្តមបណ្ឌិត បុង សុវត្ថិ | អនុប្រធាន |
| ៤. ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវត្ថ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោក យុន អាន | សមាជិក |
| ៦. លោក ម៉ាន់ វីរៈ | សមាជិក |
| ៧. លោក កែវ កាន់វីរៈ | សមាជិក |

អនុគណៈកម្មការនេះ មានភារៈកិច្ច ដូចខាងក្រោម៖
- រៀបចំខ្លឹមសារ សន្ទរកថា លិខិតបទដ្ឋាន និងឯកសារផ្សព្វផ្សាយនានា
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្រួលក្នុងការរៀបចំមហោស្រព។
- រៀបចំលិខិតអញ្ជើញគណៈអធិបតី ភ្ញៀវកិត្តិយស សិស្ស និស្សិត និងទស្សនិកជន។
- រៀបចំ និងសម្របសម្រួលធ្វើលិខិតអញ្ជើញសិល្បករ សិល្បការិនី នៃបណ្តាប្រទេសអាស៊ាន
- រៀបចំកន្លែងស្នាក់នៅ ហូបចុក និងមធ្យោបាយធ្វើដំណើរជូនគណៈប្រតិភូ
- រៀបចំសម្ភារៈ និងផ្គត់ផ្គង់ដល់មហោស្រព

**២. អនុគណៈកម្មការបច្ចេកទេស**

| | |
|---|---|
| ១. ឯកឧត្តម សំរាំង កំសាន្ត | ប្រធាន |
| ២. ឯកឧត្តម គង់ កន្ថារ៉ា | អនុប្រធាន |
| ៣. ឯកឧត្តម ហាប់ ទូច | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តមបណ្ឌិត សំអាង សម | សមាជិក |
| ៥. លោក ងួន សំអាត | សមាជិក |
| ៦. លោក ប៉ុក សារ៉ាន់ | សមាជិក |
| ៧. លោក ម៉ៅ កេង | សមាជិក |
| ៨. លោក ស៊ិន ច័ន្ទសាយ៉ា | សមាជិក |
| ៩. លោក ដេត ស៊ីវុត្ថា | សមាជិក |

អនុគណៈកម្មការនេះ មានភារៈកិច្ច ដូចខាងក្រោម៖
- រៀបចំសិល្បៈទស្សនីយភាព ដើម្បីសម្តែងក្នុងព្រឹត្តិការណ៍មហោស្រព
- រៀបចំកម្មវិធី និងលក្ខណៈបច្ចេកទេស
- រៀបចំផ្ទាំងសញ្ញារូបភាព បដា និងស្ទីគផ្សព្វផ្សាយ

## ៣. អនុគណៈកម្មការបដិសណ្ឋារកិច្ច និងពិធីការ

| | | |
|---|---|---|
| ១. លោក កែវ កាន់វីរៈ | ប្រធាន |
| ២. លោក អ៊ិន សុខា | អនុប្រធាន |
| ៣. លោកស្រី ហ៊ុន ប៉ែន | សមាជិក |
| ៤. លោក យ៉ា ដា | សមាជិក |
| ៥. កញ្ញា ជា ណារិន | សមាជិក |
| ៦. លោក ស៊ុន មានជ័យ | សមាជិក |
| ៧. លោក គង់ សុទ្ធារិទ្ធិ | សមាជិក |
| ៨. លោកស្រី សែម ឆវី | សមាជិក (ពិធីការិនី) |
| ៩. លោក ប៊ុនថន សុខាណារិទ្ធ | សមាជិក (ពិធីករ) |
| ១០. លោក ត្រឡុង បូរិន | សមាជិក (អ្នកថតរូបFixed) |
| ១១. លោក អ៊ុំ គឹមឡេង | សមាជិក (អ្នកថតVideo) |

អនុគណៈកម្មការនេះ មានភារៈកិច្ច ដូចខាងក្រោម៖

- រៀបចំបដិសណ្ឋារកិច្ច ទទួល និងជូនដំណើរគណៈប្រតិភូ
- រៀបចំការថតរូប និងអាល់ប៊ុមសម្រាប់ជូនគណៈប្រតិភូ និងរក្សាទុកជាឯកសារ
- រៀបចំថតវីដេអូ និងផលិតជា DVD សម្រាប់ជូនគណៈប្រតិភូ និងរក្សាទុកជាឯកសារ

**ប្រការ៣**: អនុគណៈកម្មការនេះ មានសិទ្ធិអញ្ជើញអង្គភាព និងមន្ត្រីពាក់ព័ន្ធចូលរួមប្រជុំ និងរៀបចំព្រឹត្តិការណ៍មហោស្រពតាមការចាំបាច់។

**ប្រការ៤**: អនុគណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមការងារបន្ថែម និងធ្វើបញ្ជីឈ្មោះស្នើសុំសេចក្តីសម្រេចពីគណៈកម្មការកណ្តាល ក្នុងគោលបំណងឱ្យដំណើរការនៃមហោស្រព នេះប្រព្រឹត្តទៅបានរលូន និងទទួលបានជោគជ័យខ្ពស់។

**ប្រការ៥**: រាល់ការចំណាយផ្សេងៗរបស់លេខាធិការដ្ឋាន និងក្រុមការងារនីមួយៗ ត្រូវធ្វើគម្រោងចំណាយលម្អិតឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំសេចក្តីសម្រេចពីថ្នាក់ដឹកនាំ។

**ប្រការ៦**: នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងប្រធាននាយកដ្ឋានពាក់ព័ន្ធទាំងអស់ ព្រមទាំងសាមីខ្លួនត្រូវអនុវត្តតាមតួនាទី និងភារៈកិច្ច ដូចមានចែងក្នុងសេចក្តីសម្រេចនេះ ឱ្យទទួលបានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

ភឿង - សកុណា

<u>ចម្លងជូន</u>

- ខុទ្ទកាល័យលោកជំទាវរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- នាយកដ្ឋានពាក់ព័ន្ធ

"ដើម្បីជ្រាប និងអនុវត្ត"

- ឯកសារ-កាលប្បវត្តិ